ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥ សសរ

**សារលិខិត**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព**

**ក្នុងឱកាសទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិ លើកទី៣៦**

**ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨**

- *សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី*
- *បងប្អូននិងក្មួយៗជនមានពិការភាព ជនរួមជាតិ ជាទីស្នេហា!*

ក្នុងឱកាសដ៏មហោឡារិកនៃទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៣៦ នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព សូមសម្តែងនូវការអបអរសាទរចំពោះការប្រារព្ធទិវាដ៏មានសារសំខាន់នេះ។ ទិវាជនមានពិការភាពកម្ពុជា និងទិវាជនមានពិការភាពអន្តរជាតិឆ្នាំ២០១៨នេះ ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ "**លើកកម្ពស់សិទ្ធិជនមានពិការភាព ធានាដល់ការធ្វើបរិយាប័ន្ននិងសមភាព**" ក្នុងគោលបំណងដើម្បីអបអរសាទរភាពជោគជ័យនៃវិស័យពិការភាពនៅកម្ពុជា ហើយបន្តបង្ហាញឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិនិងការចូលរួមរបស់ជនមានពិការភាព ធានាដល់ការធ្វើបរិយាប័ន្ន និងចលនានៃវិស័យពិការភាព ដើម្បីទទួលបានស័ក្តិសិទ្ធិភាពនៃការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨។

រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិការដ្ឋយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីលើកស្ទួយវិស័យពិការភាពនៅកម្ពុជា សំដៅជួយដល់ជនមានពិការភាពនិងក្រុមគ្រួសារឱ្យទទួលបានគុណភាពជីវិតល្អប្រសើរ គ្មានការរើសអើង ទទួលបានសេវាសង្គមនិងសេវាសាធារណៈប្រកបដោយគុណភាព រួមទាំងជំរុញឱ្យជនមានពិការភាពបានចូលរួមគ្រប់សកម្មភាពក្នុងសង្គម ទាំងការទៅចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត ការទទួលបានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ព្រមទាំងការគិតគូរដាក់បញ្ចូលបញ្ហាពិការភាពក្នុងគ្រប់វិស័យ តាមរយៈការកែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្ត ការចុះផ្សព្វផ្សាយការយល់ដឹងអំពីវិស័យពិការភាពទៅគ្រប់ក្រសួងស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ជនមានពិការភាពគ្រប់រូបនៅកម្ពុជា។

ដើម្បីធានាដល់ការធ្វើបរិយាប័ន្ននិងសមភាពសម្រាប់ជនមានពិការភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ដែលបានអនុវត្តប្រកបដោយភាពជោគជ័យនិងត្រៀមបន្តកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ក្នុងទិសដៅឈានទៅលុបបំបាត់រាល់ទម្រង់កេងប្រវ័ញ្ចនិងរើសអើងលើជនមានពិការភាព ហើយធ្វើយ៉ាងណាឱ្យជនមានពិការភាពកាន់តែទទួលបាននូវការគាំទ្រពីសង្គម បង្កើនគុណភាពជីវិតឱ្យកាន់តែប្រសើរឡើង ទទួលបានការយកចិត្តទុកដាក់ស្របតាមច្បាប់ជាតិនិងលិខិតបទដ្ឋានអន្តរជាតិដើម្បីសង្គមមួយមានសិទ្ធិស្មើគ្នា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលមានឆន្ទៈខ្ពស់ក្នុងការរុះរោយឧបសគ្គនានាដើម្បីបង្កើនឱកាសដល់ជនមានពិការភាពរួមទាំងបង្កើតនូវយុទ្ធនាការប្រើប្រាស់ភាសាលើកទឹកចិត្តដល់ជនមានពិការភាព ដោយមិនអនុញ្ញាតឱ្យប្រើពាក្យអសុរសក្នុងន័យប្រមាថ មាក់ងាយ និងរើសអើងជនមានពិការភាព ដែលផ្ទុយនឹងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការដែលបានប្រកាសដាក់ឱ្យប្រើប្រាស់តាំងពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩មក។

ទន្ទឹមនឹងនេះ សុខុមាលភាពរបស់ជនមានពិការភាព ក៏ត្រូវបានយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន ស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍរីកចម្រើនរបស់ប្រទេសជាតិ។ ជនមានពិការភាព ត្រូវបានផ្តល់អាទិភាពក្នុងការជ្រើសរើសឱ្យចូលបម្រើការងារនៅក្នុងក្រសួង ស្ថាប័នរដ្ឋ ចំនួន៤០ ដោយគិតក្នុងឆ្នាំ២០១៨នេះ ជនមានពិការភាពបានចូលបម្រើការងារសរុបចំនួន **២,៨៣៩**នាក់ ស្ត្រីមានពិការភាពចំនួន**៧៥៦**នាក់ ក្នុងនោះពិការកម្រិតធ្ងន់មានចំនួន **១,៤៧៨**នាក់ ដែលក្នុងម្នាក់គិតស្មើនឹងចំនួន២នាក់ មានចំនួនសរុប **៤,៤៧១**នាក់ ស្មើនឹង **១.៩៣** ភាគរយ ហើយបច្ចុប្បន្នគ្រប់ក្រសួងស្ថាប័នរដ្ឋកំពុងជ្រើសរើសឱ្យគ្រប់តាមអត្រាកំណត់ចំនួន ២ ភាគរយ នៅក្នុងឆ្នាំ២០១៩។

ជនមានពិការភាពក្រីក្រនៅតាមសហគមន៍ ចំនួន ៨,៧០០នាក់ និងកំពុងទទួលនូវផលប្រយោជន៍តាមរយៈការអនុវត្តការផ្តល់របបគោលនយោបាយ ដើម្បីចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានា ទាក់ទិននឹងការកាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានផ្តល់កម្មសិទ្ធិដីធ្លីនិងបានកសាងលំនៅឋានជូនជនមានពិការភាពតាកែនកោះស្លា តំបន់អភិវឌ្ឍជនមានពិការភាពខេត្តកំពត ៣១៧ នៅស្រុកគូលែន ខេត្តសៀមរាប និងនៅភ្នំធំត្រ ខេត្តបន្ទាយមានជ័យ។ យើងក៏បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍និងគាំទ្រជនមានពិការភាពចងក្រងក្រុមជួយខ្លួនឯង ចងក្រងអង្គការជនមានពិការភាពថ្នាក់ឃុំ ស្រុក ខេត្ត ក្នុងទិសដៅឱ្យជនមានពិការភាពអាចជួយគ្នាទៅវិញទៅមក រៀបចំផែនការក្នុងការដាក់បញ្ចូលវិស័យពិការភាពជាមួយអាជ្ញាធរមូលដ្ឋានថ្នាក់ឃុំ ស្រុក និងខេត្ត ជាពិសេសចូលរួមចំណែកជួយដល់ជនមានពិការភាពក្រីក្រ ក្នុងការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយឯករាជ្យស្មើភាព ស្មើសិទ្ធិ និងសេចក្តីថ្លៃថ្នូរ។ រហូតមកដល់បច្ចុប្បន្ន ជនមានពិការភាពបានចងក្រុមជួយខ្លួនឯងចំនួន១៩៥០ក្រុម អង្គការជនមានពិការភាព ចំនួន៧០ ជនមានពិការភាពប្រមាណចំនួន ២៨,០០០នាក់ ក្នុងមួយឆ្នាំ បានទទួលការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងជនមានពិការភាពចំនួន ៣៦៣នាក់ បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនិងមុខរបរក្នុងឆ្នាំ២០១៨។ ជនមានពិការភាពក្រីក្រនៅតាមសហគមន៍បាននិងកំពុងទទួលនូវផលប្រយោជន៍ជាច្រើនដូចជា ការពិនិត្យព្យាបាលនិងការថែទាំសុខភាព ការទទួលសេវាស្តារលទ្ធភាពពលកម្ម ថ្លៃអាហារហូបចុក សោហ៊ុយធ្វើដំណើរ ការស្នាក់នៅដោយឥតគិតថ្លៃ នៅខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយជាតិគាំពារសង្គម ផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានាដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ។ យើងក៏បានរៀបចំបង្កើតឱ្យមានអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនមានពិការភាពភ្នែក និងមនុស្សគថ្លង់ ដោយបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៃវិស័យអប់រំនិងព័ត៌មានវិទ្យា ព្រមទាំងបានបកប្រែជាភាសាសញ្ញានៅតាមស្ថានីយ៍ទូរទស្សន៍នានា ដើម្បីផ្តល់ឱកាសឱ្យជនមានពិការភាពទទួលបានព័ត៌មានយ៉ាងទូលំទូលាយ។ 6

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស ដើម្បីបណ្តុះបណ្តាលគ្រូថ្នាក់អប់រំពិសេសសម្រាប់ជាប្រយោជន៍ដល់សិស្សមានពិការភាព។ ជាមួយគ្នានេះ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ កុមារពិការក៏ទទួលបានការសិក្សានៅតាមគ្រឹះស្ថានសាធារណៈនិងឯកជនទូទាំងប្រទេសដូចកុមារដទៃដោយស្មើភាព និងមិនមានការរើសអើង ក្នុងនោះកុមារមានពិការភាពនៅកម្រិតមត្តេយ្យសិក្សាមានចំនួន **២,៥៤៦**នាក់ កម្រិតបឋមសិក្សា **៤៣,៣៨៤**នាក់ កម្រិតអនុវិទ្យាល័យ **៨,៩៨៨**នាក់ កម្រិតវិទ្យាល័យ **៥,៤១៩**នាក់ កម្រិតឧត្តមសិក្សា **៣៥៣**នាក់ សរុបទាំងអស់ **៦០,៦១០**នាក់។ អគារសិក្សាមួយចំនួនត្រូវបានរៀបចំឱ្យមានជម្រាលសម្រាប់សិស្សពិការ មជ្ឈមណ្ឌល និងសាលាសម្រាប់កុមារមានពិការភាពភ្នែកនិងគថ្លង់ក៏ត្រូវបានអភិវឌ្ឍ ដើម្បីឱ្យកុមារពិការភ្នែក គ ថ្លង់ សតិបញ្ញា និងពិការផ្សេងៗទៀត មានឱកាសសិក្សាអប់រំរហូតដល់កម្រិតឧត្តមសិក្សា។ យុវជនមានពិការភាពក៏ត្រូវបានលើកទឹកចិត្តឱ្យទៅប្រកួតប្រជែងជាសាកល និងមានគោលការណ៍ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំពោះជ័យលាភីជនមានពិការភាព។ បច្ចុប្បន្ននេះ ជនមានពិការភាពមួយចំនួនបានក្លាយជាបុគ្គលិកធ្វើមប្រកបដោយសមត្ថភាព ហើយគ្រូស្ម័គ្រចិត្តបង្រៀនជនមានពិការភាពនិងជនមានពិការភាពក៏ត្រូវបានលើកទឹកចិត្តផ្តល់អាទិភាព ឱ្យចូលបម្រើការងារនៅស្ថាប័នរដ្ឋ។

ដោយឡែក កាកបាទក្រហមកម្ពុជា ក៏បានផ្តល់អំណោយមនុស្សធម៌ជាថវិកាដ៏ថ្លៃថ្លា និងសម្ភារៈជាច្រើនសន្ធឹកសន្ធាប់ ដើម្បីទ្រទ្រង់សកម្មភាពរបស់សមាគម អង្គការជនមានពិការភាពនានា តួយ៉ាងដូចជា ការជួយឧបត្ថម្ភកសាងអគារស្នាក់នៅរបស់សមាគមសំនៀងតន្ត្រីជនមានពិការភាព និងបានធ្វើសកម្មភាពមនុស្សធម៌ជាច្រើនទៀត ដើម្បីជួយដល់ចាស់ជរា ស្ត្រីមេម៉ាយ កុមារកំព្រា ជនអនាថា អ្នកផ្ទុកមេរោគអេដស៍ និងជនងាយរងគ្រោះផ្សេងៗទៀត ជាពិសេសជនមានពិការភាពក្រីក្រ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់នៃក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័ននានា អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងមូលនិធិជនមានពិការភាព ជាពិសេស បងប្អូនជនមានពិការភាពដែលបានចូលរួមចំណែកយ៉ាងសកម្ម និងជំរុញឱ្យមានការដាក់បញ្ចូលជនមានពិការភាពក្នុងការអភិវឌ្ឍ។

ក្នុងស្មារតីនេះ ដើម្បីចូលរួមចំណែកគាំទ្រទិវាជនមានពិការភាពកម្ពុជា លើកទី២០ និងទិវាជនមានពិការភាពអន្តរជាតិ លើកទី៣៦ ឆ្នាំ២០១៨នេះ ខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវដូចតទៅ៖

*ទី១-* គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវបន្តរៀបចំការបង្កលក្ខណៈងាយស្រួល ចេញចូលទីកន្លែងសាធារណៈសម្រាប់ជនមានពិការភាពគ្រប់ប្រភេទដូចជា៖ ការរៀបចំចំណតយានយន្តពិសេសសម្រាប់ជនមានពិការភាព ការធ្វើជម្រាល ការបំពាក់ឧបករណ៍ធ្នាក់ដៃ ទ្វារ បន្ទប់ទឹកជនមានពិការភាព ការដាក់ស្លាកសញ្ញានានា នៅតាមក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ ទីកន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកម្សាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព និងមធ្យោបាយដឹកជញ្ជូន ។ល។

*ទី២-* គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវចាត់អាទិភាពដាក់បញ្ចូលការងារពិការភាព និងកញ្ចប់ថវិកានៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ និងត្រូវរួមគ្នាអនុវត្តរបបគោលនយោបាយជាតិសន្តិសុខសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពជនមានពិការភាព។

*ទី៣-* ត្រូវបន្តជំរុញនិងយកចិត្តទុកដាក់គិតគូរអំពីផលប្រយោជន៍ និងលើកតម្កើងជីវភាពរស់នៅរបស់បងប្អូនជនមានពិការភាពឱ្យបានសមរម្យស្របតាមសេដ្ឋកិច្ចជាតិ និងត្រូវមានវិធានការណ៍ចាំបាច់នានា ដើម្បីបំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជន ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលនានា ឱ្យចូលរួមឧបត្ថម្ភជនមានពិការភាព ព្រមទាំងត្រូវលើកទឹកចិត្តដល់ជនដែលមានពិការភាពដែលប្រកបមុខរបរ អាជីវកម្ម សិប្បកម្មជាលក្ខណៈឯកត្តជន

ឬគ្រួសារ ឬសមូហភាពរបស់ជនមានពិការភាព តាមរយៈការកាត់បន្ថយពន្ធ និងការផ្តល់អាទិភាពផ្សេងៗស្រប តាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនមានពិការភាព។

*ទី៤-* គ្រប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវលើកទឹកចិត្តជនមានពិការភាពដែលមានលក្ខណសម្បត្តិ និងសមត្ថភាព បំពេញមុខងារ តួនាទី ទទួលខុសត្រូវក្នុងមុខតំណែង ឱ្យមានសិទ្ធិចូលបម្រើការងារដោយគ្មានការរើសអើង រាប់ទាំងការបម្រើការងារជាមន្ត្រីរាជការ កម្មករ និយោជិត កូនជាង ឬកម្មសិក្សាការីជាដើម។

*ទី៥-* ត្រូវបន្តលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន រោងចក្រ សហគ្រាស សណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានទាំងអស់ក្នុងការជ្រើសរើសជនមានពិការភាព ដោយការភ្ជាប់លើកអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនមានពិការភាព។

*ទី៦-* ក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព ត្រូវបន្តដឹកនាំចាត់ចែង អនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព និងជំរុញការអនុវត្តលិខិតបទដ្ឋានអន្តរជាតិពាក់ព័ន្ធពិការភាពជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ឱ្យដំណើរការទៅបានដោយរលូននិងប្រកបដោយប្រសិទ្ធភាព ព្រមទាំងត្រូវធ្វើរបាយការណ៍ជាក់ជូនរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ។

*ទី៧-* ក្រសួងព័ត៌មាន ត្រូវធ្វើការណែនាំដល់គ្រប់ស្ថានីយវិទ្យុនិងទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងគ្រប់ប្រព័ន្ធសារព័ត៌មាន សូមបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការយកចិត្តទុកដាក់ និងលើកកម្ពស់សុខុមាលភាពជនមានពិការភាពនៅកម្ពុជា ជាពិសេសត្រូវមានការបកប្រែជាភាសាសញ្ញា និងអក្សររត់នៅតាមបណ្តាស្ថានីយទូរទស្សន៍ ដើម្បីសម្រួលដល់ជនមានពិការភាពក្នុងការទទួលបានព័ត៌មានផ្សេងៗ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី បងប្អូន ក្មួយៗ ជនមានពិការភាព និងជនរួមជាតិទាំងអស់ សូមប្រកបបាននូវពុទ្ធពរប្រាំប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ១១ រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**